# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 57 PR-18 / EoJ                    កាលបរិច្ឆេទ: ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨

**“កម្មវិធីផ្លាស់ប្តូរយុវជន JENESYS ២០១៨”**
**(ប្រធានបទ: លទ្ធិប្រជាធិបតេយ្យពហុបក្សជប៉ុន )**

១. យុវជនកម្ពុជាដែលមានចំណាប់អារម្មណ៍ផ្នែកនយោបាយចំនួន ១០ រូប នឹងមកធ្វើទស្សនកិច្ចនៅប្រទេសជប៉ុនក្រោមកម្មវិធីផ្លាស់ប្តូរយុវជន (JENESYS) ឆ្នាំ២០១៨ ចាប់ពីថ្ងៃទី ២ ដល់ ៨ ខែធ្នូ ឆ្នាំ ២០១៨ ។

២. ក្រោមប្រធានបទ “លទ្ធិប្រជាធិបតេយ្យពហុបក្សជប៉ុន” យុវជនទាំងនេះ នឹងចូលរួមបាឋកថាផ្សេងៗ និងធ្វើទស្សនកិច្ចនៅរដ្ឋសភា និងស្ថាប័នដទៃទៀតនៅទីក្រុងតូក្យូ ។ បន្ទាប់មក យុវជនទាំងអស់នឹងទៅធ្វើទស្សនកិច្ចនៅខេត្ត អ៊ីបារ៉ាគិ (Ibaraki) និងសង្កេតមើលការងារការបោះឆ្នោតសភាថ្នាក់មូលដ្ឋាន ហើយនឹងមានឱកាសធ្វើទស្សនកិច្ចនៅទីកន្លែងល្បីល្បាញ និងសំណង់ប្រវត្តិសាស្ត្រនានានៅតាមតំបន់និមួយៗ ដើម្បីបានយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រទេសជប៉ុន។

៣. តាមរយៈកម្មវិធីនេះ យើងរំពឹងថា យុវជនទាំងនោះ ដែលនឹងដឹកនាំអនាគតនៃប្រទេសកម្ពុជា នឹងស្វែងយល់កាន់តែស៊ីជម្រៅអំពីលទ្ធិប្រជាធិបតេយ្យពហុបក្សជប៉ុនទុកជាចំណេះដឹងសំរាប់អភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។

* អត្ថបទខាងលើនេះ គឺជាការបកប្រែក្រៅផ្លូវការ ។ កាលបរិច្ឆេទដែលបានបញ្ជាក់ខាងលើ គឺជាកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសព័ត៌មានដើមជាភាសាជប៉ុន ។

* សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានអាស៊ីអាគ្នេយ៍ទី ១ នៃក្រសួងការបរទេសជប៉ុន តាមទូរសព្ទលេខ ៥៥០១-៨០០០ (លេខបន្ទះ ២៤៣៨)។

---


*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162; Email: japan.embassy@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*

**កម្មវិធីចំណងមិត្តភាពរបស់ប្រទេសជប៉ុន “កម្មវិធីផ្លាស់ប្តូរយុវជន JENESYS ២០១៨”**
**កម្មវិធីដំណើរទស្សនកិច្ចសំរាប់យុវជនអាស៊ាន (លើកទី ១៥)**
**(ប្រទេស: កម្ពុជា, ប្រធានបទ: លទ្ធិប្រជាធិបតេយ្យពហុបក្សជប៉ុន )**

**<u>កាលវិភាគនៃកម្មវិធី</u>**

ថ្ងៃអាទិត្យ ទី ២ ខែធ្នូ
មកដល់ប្រទេសជប៉ុន និងការណែនាំផ្សេងៗ

ថ្ងៃច័ន្ទ ទី ៣ ដល់អង្គារទី ៤ ខែធ្នូ
ធ្វើទស្សនកិច្ចនៅក្រសួងការបរទេស
ចូលរួមកម្មវិធីបាឋកថាដោយអ្នកជំនាញការ
ធ្វើទស្សនកិច្ចនៅរដ្ឋសភា

ថ្ងៃពុធ ទី ៥ ខែធ្នូ
ធ្វើទស្សនកិច្ចនៅខេត្ត អ៊ីបារ៉ាគិ ។ ការពន្យល់ដោយគណៈកម្មាការគ្រប់គ្រងការបោះឆ្នោត នៃខេត្តអ៊ីបារ៉ាគិ និងទីក្រុងមិតុ ។ សង្កេតមើលដំណើរការឃោសនាបោះឆ្នោត ។ល។

ថ្ងៃព្រហស្បត៍ ទី ៦ ខែធ្នូ
ជួបជាមួយនឹងជនជាតិជប៉ុនដែលធ្លាប់ចូលរួមពាក់ព័ន្ធក្នុងដំណើរការស្វែងរកសន្តិភាពនៅ កម្ពុជា ។
ជួបជាមួយនឹងអ្នកសារព័ត៌មានជប៉ុន ។

ថ្ងៃសុក្រ ទី ៧ ខែធ្នូ
ទស្សនាទីក្រុងតូក្យូ សិក្ខាសាលា ប្រជុំរាយការណ៍ ។

ថ្ងៃសៅរ៍ ទី ៨ ខែធ្នូ
ចេញដំណើរត្រឡប់ទៅវិញ ។